វិទ្យាស្ថានសភាកម្ពុជា
PARLIAMENTARY INSTITUTE OF CAMBODIA
STRENGTHENING PARLIAMENTARY CAPACITY

# ព្រឹត្តប័ត្រព័ត៌មានសង្ខេប

**សប្តាហ៍ដែលបញ្ចប់**
**ថ្ងៃទី ០១ ខែ មីនា ២០១៨**

ចំណុចសំខាន់ៗ អំពីព័ត៌មានសេដ្ឋកិច្ច និងការអភិវឌ្ឍសារពើពន្ធនៅក្នុងបណ្តាប្រទេសជាសមាជិកអាស៊ាន និងនៅប្រទេសផ្សេងៗទៀត នៅក្នុងសប្តាហ៍នេះ គឺះ

- ការចំណាយរបស់អ្នកប្រើប្រាស់ទៅលើគ្រឿងអេឡិចត្រូនិចនៅកម្ពុជា កើនឡើង ៣០% នៅឆ្នាំ ២០១៨
- ប្រទេសឡាវ សម្លឹងមើលឱកាសបង្កើនការនាំចេញស្ករទៅកាន់ប្រទេសចិន
- ធនាគារកណ្តាលរំពឹងថាអតិផរណានៅអាមេរិកនឹងបន្តធ្លាក់ទាបជាង គោលដៅដែលបានកំណត់

*ព្រឹត្តប័ត្រសង្ខេបព័ត៌មាននេះ គឺជាព្រឹត្តិប័ត្រប្រចាំសប្តាហ៍ដែលរៀបចំឡើងដើម្បីតាមដានព័ត៌មានអំពីការអភិវឌ្ឍសេដ្ឋកិច្ច និងសារពើពន្ធថ្មីៗនៅក្នុងប្រទេសកម្ពុជា និងដៃគូពាណិជ្ជកម្មនានា។ ឯកសារនេះត្រូវបានធ្វើឡើងដោយក្រុមការងារបណ្តុះបណ្តាលសមត្ថភាពការវិភាគសារពើពន្ធរបស់វិទ្យាស្ថានសភាកម្ពុជា ក្នុងគោលបំណងពង្រឹងជំនាញនៃការធ្វើឯកសារ និងការស្រាវជ្រាវរបស់ខ្លួន។ ការងារនេះត្រូវបានព្យាយាមធ្វើឡើងដើម្បីធានាថាការវិភាគ និងអត្ថន័យ ដែលបានផ្តល់នៅក្នុងឯកសារនេះ មានគុណភាពខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ សូមអ្នកអានចាត់ទុកឯកសារនេះជាផ្នែកមួយនៃលំហាត់អនុវត្តនៅក្នុងកំឡុងពេលនៃការបណ្តុះបណ្តាល។ យើងមិនអាចធានាថាឯកសារនេះល្អឥតខ្ចោះនោះទេ។*

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការចំណាយរបស់អ្នកប្រើប្រាស់ទៅលើគ្រឿងអេឡិចត្រូនិច កើនឡើង ៣០% នៅឆ្នាំ ២០១៨

ប្រជាជនកម្ពុជាបានចំណាយប្រាក់ចំនួន ៤១៣ លានដុល្លារអាមេរិក លើគ្រឿងអេឡិចត្រូនិច កាលពីឆ្នាំមុន ដែលកើនពី ៣២៣ លានដុល្លារពីឆ្នាំ២០១៧ នេះបើយោងតាមក្រុមហ៊ុនស្រាវជ្រាវទីផ្សារ GfK ដែលបានលើកឡើងដោយលោក សុខ ពិសិដ្ឋ នាយកប្រតិបត្តិក្រុមហ៊ុន ជីហ្គៀ(G-Gear) និងក្រុមហ៊ុនអេឡិចត្រូនិច LG នៅក្នុងកាសែតភ្នំពេញប៉ុស្តិ៍។ ស្ទើរតែ ៧០% នៃចំនាយលើអេឡិចត្រូនិចសរុបនេះ គឺជាការចំណាយទៅលើទូរស័ព្ទចល័ត (២៨២លានដុល្លារ)។

ការកើនឡើងនេះបណ្តាលមកពីកំណើនប្រាក់ចំណូល និងកម្រិតជីវភាពយ៉ាងឆាប់រហ័ស កំណើនតម្រូវការឧបករណ៍ប្រើប្រាស់ក្នុងផ្ទះ ដូចជាទូរទស្សន៍ ទូទឹកកក និងម៉ាស៊ីនបោកគក់ ជាដើម។ គម្រោងការទិញបណ្តាក់ដែលផ្តល់ជម្រើសច្រើន ក៏បានរួមចំណែកធ្វើអោយការលក់កើនឡើងដែរ ដែលមានភាពអំណោយផលដល់អ្នកប្រើប្រាស់ដោយពុំចាំបាច់ចំណាយលុយទាំងស្រុងមុន ដើម្បីទទួលទំនិញបានភ្លាមៗនោះទេ និងគ្រាន់តែចំណាយបន្តិចម្តងៗជាប្រចាំប៉ុណ្ណោះ។

### តារាងប្រចាំសប្តាហ៍៖ ពិន្ទុសន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្ស (HDI score) នៅបណ្តាប្រទេសក្នុងអាស៊ាន ឆ្នាំ ២០១៧

តារាសប្តាហ៍នេះបង្ហាញពីការប្រៀបធៀបសន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្ស (Human Development Index) នៅបណ្តាប្រទេសក្នុងអាស៊ាន ក្នុងឆ្នាំ២០១៧។ សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្ស(HDI) គឺជារង្វាស់នៃសមិទ្ធិផលជាមធ្យម លើទិដ្ឋភាពទាំងបីនៃការអភិវឌ្ឍធនធានមនុស្ស ដូចជា៖ ស្ថានភាពសុខភាព, ការអប់រំ និងបទដ្ឋាននៃការរស់នៅ។ ពិន្ទុនៃសន្ទស្សន៍របស់ប្រទេសមួយកាន់តែខ្ពស់ មានន័យថា កម្រិតនៃការអភិវឌ្ឍធនធាន

មនុស្សរបស់ប្រទេសនោះកាន់តែប្រសើរឡើងដែរ ផ្ទុយមកវិញ ប្រទេសដែលមានពិន្ទុHDIកាន់តែទាប ការអភិវឌ្ឍធនធានមនុស្ស របស់ប្រទេសនោះក៏មានកម្រិតទាបដែរ។

ប្រទេសសិង្ហបុរី មានពិន្ទុHDIខ្ពស់ជាងគេក្នុងចំណោមបណ្ដាប្រទេសក្នុងអាស៊ាន ក្នុងឆ្នាំ២០១៧ ខណៈពេលដែលកម្ពុជា និងមីយ៉ាន់ម៉ា ស្ថិតនៅលំដាប់ទាបជាងប្រទេសអាស៊ានជាដៃគូ។ ពិន្ទុHDI នៅប្រទេសកម្ពុជា មានចំនួន ០,៥៨ ដែលស្ថិតនៅលេខរៀងទី១៤៦ ក្នុងចំណោម ១៨៩ប្រទេស។

**ពិន្ទុHDI នៅបណ្ដាប្រទេសក្នុងអាស៊ាន ឆ្នាំ ២០១៧**




ប្រភព៖ កម្មវិធីអភិវឌ្ឍអង្គការសហប្រជាជាតិ (UNDP)

## ព័ត៌មាន និងទិន្នន័យរបស់បណ្ដាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ប្រទេសឡាវ សម្លឹងមើលឱកាសបង្កើនការនាំចេញស្ករទៅកាន់ប្រទេសចិន

ក្នុងអំឡុងពេលគណៈប្រតិភូចិន ធ្វើទស្សនកិច្ចទៅកាន់ប្រទេសឡាវ មន្ត្រីឡាវ បានលើកឡើងនូវសំណើឲ្យចិនបើកទីផ្សាររបស់ខ្លួនទៅលើផលិតផលកសិកម្មឡាវបន្ថែមទៀត ជាពិសេសលើផលិតផលស្ករ ដោយបង្កើនការអនុញ្ញាតនាំចូលពី ៥៥ 000 តោន នៅឆ្នាំ ២០១៨ ទៅ ១០០ 000តោន ក្នុងឆ្នាំ ២០១៩។

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងពាណិជ្ជកម្មឡាវបានស្នើ ឲ្យមានការបង្កើននេះ ស្របពេលដែលមានគម្រោងធំៗ រវាងឡាវ និងចិន ដូចជាផ្លូវរថភ្លើងឡាវ-ចិន ជាដើម។

តម្លៃពាណិជ្ជកម្មនៃការនាំចេញរបស់ឡាវ ទៅកាន់ប្រទេសចិន ក្នុងកំឡុងពេលប្រាំមួយខែ ដំបូងនៃឆ្នាំមុន មានចំនួន ៦១៩លានដុល្លារអាមេរិក តិចជាងច្រើន ធៀបនឹងទំនិញដែលឡាវបានលក់ទៅប្រទេសថៃ ដែលមានប្រមាណ១,២៧ប៊ីលានដុល្លារ។

ការលក់អង្កររបស់ឡាវទៅអោយចិនបានធ្លាក់ចុះពី ១៤,២លានដុល្លារ នៅឆ្នាំ២០១៦ ទៅ ៥,៦លានដុល្លារក្នុងឆ្នាំ២០១៧ និងបន្តធ្លាក់ចុះទៅ៥លានដុល្លារ នៅឆ្នាំ ២០១៨។ បើទោះបីជាមានការធ្លាក់ចុះក៏ដោយ ក៏ប្រទេសចិននៅតែជាទីផ្សារនាំចេញអង្ករដ៏ធំបំផុតរបស់ប្រទេសឡាវ និងជាដៃគូពាណិជ្ជកម្មដ៏ធំបំផុតទី២ របស់ប្រទេសឡាវផងដែរ។

## សេដ្ឋកិច្ចសហរដ្ឋអាមេរិក និងទុនបម្រុងសហព័ន្ធ

### ធនាគារកណ្ដាលរំពឹងថាអតិផរណានៅអាមេរិកនឹងបន្តធ្លាក់ទាបជាង គោលដៅដែលបានកំណត់

កាលពីថ្ងៃអង្គារ ប្រធានធនាគារកណ្ដាលលោក Jerome Powell បានប្រកាសថា៖ ការិយាល័យរបស់លោករំពឹងថា អតិផរណានឹងធ្លាក់ចុះបន្ថែមទៀត រហូតនៅក្រោមគោលដៅអតិផរណា២% របស់ធនាគារ បើទោះបីជាមានកំណើនសេដ្ឋកិច្ច និងកំណើនការងាររឹងមាំក៏ដោយ។

ទស្សនវិស័យអតិផរណារបស់ធនាគារកណ្ដាលអាមេរិក បានបង្ហាញថា វិធីសាស្ត្រ "រង់ចាំមើល" របស់គណៈកម្មាធិការទីផ្សារបើកទូលាយ លើការតំឡើងអត្រាការប្រាក់នឹងបន្តក្នុងរយៈវែងជាងការរំពឹងទុក ស្របពេលដែលអ្នកសេដ្ឋកិច្ចជាច្រើន មិនរំពឹងថា នឹងមានការកើនឡើងបន្តទៀតទេ នៅឆ្នាំនេះ។

ទោះបីជាប្រតិកម្មពីទីផ្សារមានភាពយឺតយ៉ាវក្ដី ការកើនឡើងអត្រាតិចតួច មានន័យថា ប្រាក់ដុល្លារអាមេរិកនឹងកាន់តែធ្លាក់ចុះនៅឆ្នាំខាងមុខនេះ។ ខណៈពេលដែលកម្ពុជាភ្ជាប់រូបិយប័ណ្ណរបស់ខ្លួនទៅនឹងប្រាក់ដុល្លារអាមេរិក មានន័យថាប្រាក់រៀលកាន់តែធ្លាក់ចុះដែរ ដែលផ្ដល់ទស្សនវិស័យវិជ្ជមានសម្រាប់ការនាំចេញ និង ផ.ស.ស របស់ប្រទេសកម្ពុជា។

## ព័ត៌មានសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ ផលិតផលក្នុងស្រុកសរុបនៅក្នុងប្រទេសកូរ៉េខាងត្បូង និងជប៉ុន, អតិផរណា នៅក្នុងប្រទេសកូរ៉េខាងត្បូង, ហ្វីលីពីន និងប៉េរ៉ុយណេ។

ខាងក្រោមគឺជាប្រតិទិនពេញលេញនៃការចេញនូវទិន្នន័យ និងការអភិវឌ្ឍ ដែលក្រុម FACT នឹងបន្តតាមដាននៅសប្តាហ៍ក្រោយ៖

<u>ថ្ងៃច័ន្ទ ទី០៤ ខែមីនា</u>

- តុល្យភាពពាណិជ្ជកម្មរបស់ ម៉ាឡេស៊ី សម្រាប់ខែមករា
- ការចំណាយទៅលើការសាងសង់ នៅអាមេរិក សម្រាប់ខែធ្នូ

<u>ថ្ងៃអង្គារ ទី០៥ ខែមីនា</u>

- ផលិតផលក្នុងស្រុកសរុបរបស់កូរ៉េខាងត្បូង សម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៨
- អតិផរណា នៅកូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- អតិផរណា នៅហ្វីលីពីន សម្រាប់ខែកុម្ភៈ
- ផលិតផលឧស្សាហកម្ម នៅហ្វីលីពីន សម្រាប់ខែមករា
- ការសម្រេចចិត្តនូវអត្រាការប្រាក់របស់ម៉ាឡេស៊ី

<u>ថ្ងៃពុធ ទី០៦ ខែមីនា</u>

- ទំនុកចិត្តអតិថិជននៅឥណ្ឌូណេស៊ី សម្រាប់ខែកុម្ភៈ
- ទុនបម្រុងអន្តរជាតិ កូរ៉េខាងត្បូង សម្រាប់ខែកុម្ភៈ
- តុល្យភាពពាណិជ្ជកម្មរបស់ អាមេរិក សម្រាប់ខែ ធ្នូ

<u>ថ្ងៃព្រហស្បត្តិ៍ ទី០៧ ខែមីនា</u>

- ការវិនិយោគមូលបត្របំណុលបរទេស របស់ជប៉ុន សម្រាប់ថ្ងៃទី០២ ខែមីនា
- អត្រាភាពគ្មានការងារធ្វើនៅហ្វីលីពីន សម្រាប់ត្រីមាសទី១ ឆ្នាំ២០១៩
- អតិផរណានៅប៉េរ៉ុយណេ សម្រាប់ខែមករា
- ទុនបំរុងរូបិយបណ្ណបរទេសរបស់ចិន សម្រាប់ខែកុម្ភៈ

<u>ថ្ងៃសុក្រ ទី០៨ ខែមីនា</u>

- គណនីចរន្ត របស់កូរ៉េខាងត្បូង សម្រាប់ខែមករា
- ការចំណាយរបស់គ្រួសារនៅជប៉ុន សម្រាប់ខែមករា
- ផលិតផលក្នុងស្រុកសរុប របស់ជប៉ុន តាមរយៈការប៉ាន់ស្មានចុងក្រោយ សម្រាប់ត្រីមាសទី៤ ឆ្នាំ ២០១៨
- ភាពគ្មានការងារធ្វើរបស់អាមេរិក សម្រាប់ខែ កុម្ភៈ